# ហេតុអ្វីខ្មែរក្រហមជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ?

ដោយៈ ចាន ប្រាថ្នា

ពិនិត្យដោយៈ វ៉ាន់ថាន់ ពៅដារ៉ា

នៅថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០១៣ នួន ជា បានថ្លែងថា មូលហេតុដែលថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជាសម្រេចជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញកាលពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ព្រោះខ្លាចមានការទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិកមកលើប្រជាជននៅក្នុងទីក្រុងបន្ទាប់ពីរបប លន់ នល់ ត្រូវបានផ្តួលរំលំ ។ ហេតុផលមួយទៀត គឺដើម្បីឲ្យប្រជាជននៅក្នុងទីក្រុងចូលរួមបង្កបង្កើនផលនៅតាមជនបទ ។[1] ពិតប្រាកដណាស់ ដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សីជាច្រើនរូបបានផ្តល់សក្ខីកម្មដូចៗគ្នានៅចំពោះមុខតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមថា បន្ទាប់ពីយោធាខ្មែរក្រហមចូលកាន់កាប់ទីក្រុងភ្នំពេញភ្លាម ខ្មែរក្រហមបានប្រកាសឲ្យប្រជាជនចេញពីទីក្រុង ដោយផ្តល់ហេតុផលថា ដើម្បីគេចពីការទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិក និងរៀបចំទីក្រុងឲ្យមានរបៀបរៀបរយ ហើយបីថ្ងៃក្រោយទើបអនុញ្ញាតឲ្យចូលទីក្រុងភ្នំពេញវិញ ។

តើមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាពិតជាមានការភ័យខ្លាចថា មានការទម្លាក់គ្រាប់បែកពីសំណាក់សហរដ្ឋអាមេរិក ដូចបានប្រកាសនៅក្នុងអំឡុងពេលជម្លៀសប្រជាជនរាប់លាននាក់ចេញពីទីក្រុង (ដែលជាព្រឹត្តិការណ៍ដ៏គួរឲ្យរន្ធត់ និងរងទុក្ខយ៉ាងធ្ងន់ធ្ងរសម្រាប់ប្រជាជនកម្ពុជា) ឬទេ? ប្រជាជនដែលបានរត់ចូលស្ថានទូតបារាំង អ្នកជំងឺកំពុងសម្រាកក្នុងមន្ទីរពេទ្យជាច្រើន ត្រូវបានបង្ខំឲ្យចាកចេញដោយគ្មានការសណ្តោសប្រណី ។

បើរំឭកទៅដល់សក្ខីកម្មរបស់ នួន ជា ក្នុងសវនាការកាលពីថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១១ បានបង្ហាញឲ្យឃើញថា ថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជាបានដឹងយ៉ាងច្បាស់ថា សភាសហរដ្ឋអាមេរិកបានអនុម័តច្បាប់មួយ ដោយហាមឃាត់រដ្ឋាភិបាលរបស់ខ្លួនដែលដឹកនាំដោយប្រធានាធិបតី រីឆាត និចសុនឲ្យបញ្ចប់ការទម្លាក់គ្រាប់បែកមកលើប្រទេសកម្ពុជាក្នុងឆ្នាំ១៩៧៣ ។[2] គណៈកម្មាធិការអចិន្ត្រៃយ៍បក្សកុម្មុយនីស្តកម្ពុជាបានវិភាគឃើញថា បើគ្មានជំនួយយោធាផ្នែកកងទ័ពជើងអាកាសរបស់សហរដ្ឋអាមេរិក

---

១-សេចក្តីថ្លែងការណ៍របស់ នួន ជា នៅក្នុងសវនាការថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០១៣ ។ អាចរកបាននៅៈ http://www.eccc.gov.kh/blog/2013/07/10/26785

២-សូមមើលប្រតិចារិកសវនាការថ្ងៃ ទី២២ ខែវិច្ឆិកា ឆ្នាំ២០១១ ឯកសារលេខ E1/14.1 ត្រង់ទំព័រ ៧៣ ។ អាចរកបានក្នុងគេហទំព័រៈ http://www.eccc.gov.kh/document/court/16108

នោះចលនាតស៊ូរបស់ខ្លួននឹងទទួលបានជ័យជំនះក្នុងពេលឆាប់ៗជាក់ជាមិនខាន ព្រោះទាហានរបស់ លន់ នល់ កាន់តែចុះខ្សោយទៅៗជាលំដាប់ ។[៣] ច្បាស់ជាងនេះទៀត ក្នុងសវនាការថ្ងៃដដែលនោះ នួន ជា បានបញ្ជាក់ថា នៅក្នុងកិច្ចប្រជុំពាក់កណ្តាលឆ្នាំ១៩៧៤ (កិច្ចប្រជុំរួមរវាងគណៈមជ្ឈិម និងគណៈអចិន្ត្រៃយ៍របស់បក្សកុម្មុយនីស្តកម្ពុជា ដែលបានសម្រេចជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ និងតាមទីរួមខេត្ត) អង្គប្រជុំបានឯកភាពគ្នាថា *«បើបក្សកុម្មុយនីស្តកម្ពុជាដឹកនាំចលនាតស៊ូរំដោះជាតិ រំដោះប្រជាជនបាន គឺយើងសម្រេចបានការកិច្ចធ្វើ 'បដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យ'[៤] បានមួយចំនួនសំខាន់ហើយ បានដោះស្រាយទំនាស់បដិបក្ខគឺទំនាស់ស្លាប់រស់ជាមួយសហរដ្ឋអាមេរិក និងរបប លន់ នល់ បានជាដំបូង ។ សហរដ្ឋអាមេរិកមិននៅជាគូអង្គបដិបក្ខទៀតទេ»* ។[៥]

ដូច្នេះ តើអ្វីជាហេតុផលពិតប្រាកដនៃការសម្រេចជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ?

សេចក្តីសម្រេចជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ គឺពុំមែនជារឿងដែលកើតឡើងភ្លាមៗ ឬដោយចៃដន្យឡើយ ។ តាមរយៈសក្ខីកម្មរបស់ នួន ជា សេចក្តីសម្រេចនេះត្រូវបានអនុម័តជាឯកច្ឆ័នទៅក្នុងកិច្ចប្រជុំរួមរវាងគណៈមជ្ឈិម និងគណៈអចិន្ត្រៃយ៍នៃបក្សកុម្មុយនីស្តកម្ពុជា (ហៅកាត់ថា អង្គប្រជុំ) ក្នុងឆ្នាំ១៩៧៤ ។[៦] ថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជាបានសម្រេចជាឯកច្ឆ័នថា *«ក្នុងករណីរំដោះបានទីក្រុងភ្នំពេញ នោះត្រូវជម្លៀសប្រជាជនចេញពីក្រុងភ្នំពេញ និងទីរួមខេត្តជាបណ្តោះអាសន្ន ដើម្បីពិនិត្យតាមដានសភាពការណ៍មួយរយៈសិន ជាពិសេសសកម្មភាពរបស់វៀតណាម»* ។[៧] ហេតុផលទីមួយ ថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជាវិភាគឃើញថា នៅពេលរំដោះបានទីក្រុងភ្នំពេញ ទាហាន លន់ នល់ មួយចំនួននឹងសម្ងំលាក់ខ្លួននៅក្នុងទីក្រុង ដែលអាចបង្កការរំខាន ឬវាយឆ្មក់មកលើកម្លាំងទ័ព និងប្រជាជនរបស់ខ្លួន ។[៨] ហេតុផលទីពីរពាក់ព័ន្ធនឹងការពិនិត្យតាមដានសកម្មភាពរបស់វៀតណាម ថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជាមានការព្រួយបារម្ភថា វៀតណាមអាចនឹងវាយដណ្តើមកាន់កាប់ទីក្រុងភ្នំពេញ បន្ទាប់ពីវៀតណាមខាង

---

៣- ឯកសារលេខ E1/14.1 ត្រង់ទំព័រ៧៣ ។

៤- អ្វីទៅដែលហៅថា«បដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យ» សូមមើលៈ http://d.dccam.org/Projects/ECCC_Trial_Observation/pdf/Policy_of_Democracy_Nation.pdf

៥- ឯកសារលេខ E1/14.1 ត្រង់ទំព័រ៧៥ បន្ទាត់ទី១១-១៤ ។

៦- សូមមើលប្រតិចារិកសវនាការថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១១ ឯកសារលេខ E1/22.1 ត្រង់ទំព័រ២ បន្ទាត់ទី២-៥ ។ អាចរកបានក្នុងគេហទំព័រៈ http://www.eccc.gov.kh/document/court/16381

៧- ឯកសារលេខ E1/14.1 ត្រង់ទំព័រ៧៧ បន្ទាត់ទី១៨-២០ ។

៨- ឯកសារលេខ E1/14.1 ត្រង់ទំព័រ៧៦ បន្ទាត់ទី១-៧ ។

ដើម្បីរំដោះបានវៀតណាមខាងត្បូង ។[៩] ថ្នាក់ដឹកនាំខ្មែរក្រហមបានវិភាគថា បន្ទាប់ពីចលនាតស៊ូរំដោះជាតិរំដោះប្រជាជនទទួលបានជោគជ័យ វៀតណាមនឹងក្លាយទៅជាគូបដិបក្ខ (ទំនាស់ស្លាប់រស់) របស់ខ្លួន គឺពុំមែនសហរដ្ឋអាមេរិកទៀតឡើយ ។[១០]

ហេតុផលមួយទៀតនៃការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ គឺដើម្បីអនុវត្តផែនការពង្រីកសហករណ៍នៅតាមមូលដ្ឋាន ។ តាមរយៈសេចក្តីសម្រេចនៅក្នុងកិច្ចប្រជុំពាក់កណ្តាលឆ្នាំ១៩៧៤ បានបង្ហាញថា បន្ទាប់ពីវាយដណ្តើមកាន់កាប់បានទីក្រុងភ្នំពេញ នោះបក្សកុម្មុយនីស្តកម្ពុជានឹងជម្លៀសប្រជាជនទៅតាមភូមិភាគនីមួយៗ ដែលភូមិភាគទាំងនោះត្រូវបានណែនាំឲ្យត្រៀមខ្លួនរួចជាស្រេចក្នុងការទទួលយកកម្លាំងបន្ថែមដើម្បីបង្កបង្កើនផល ។ ក្នុងកិច្ចប្រជុំនោះ ថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជាបានណែនាំដល់កម្មាភិបាលដែលបានចូលរួមប្រជុំទាំងអស់ ឲ្យទៅពិភាក្សាជាមួយ គណៈភូមិភាគ គណៈតំបន់ គណៈស្រុក អំពីលទ្ធភាពក្នុងការទទួលយកប្រជាជនដែលនឹងត្រូវជម្លៀសចេញពីទីក្រុងភ្នំពេញ ។[១១]

ហេតុផលខាងលើនេះ មានភាពស៊ីសង្វាក់គ្នាយ៉ាងខ្លាំងទៅនឹងបទខុទ្ទេសនាមរបស់ថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជាដែលត្រូវបានចុះផ្សាយក្នុងទស្សនាវដ្តីទង់បដិវត្ត ។ យោងតាមទស្សនាវដ្តីទង់បដិវត្តលេខពិសេសបោះពុម្ពផ្សាយសម្រាប់ខែ ធ្នូ-មករា ឆ្នាំ១៩៧៦-១៩៧៧ (ចុះផ្សាយបទខុទ្ទេសនាមរបស់ថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជា[១២] ដែលបានផ្ញើនៅថ្ងៃទី១៧ ខែ មករា ឆ្នាំ១៩៧៧ ក្នុងឱកាសថ្ងៃបុណ្យរំឭកខួបលើកទី៩ នៃកំណើតកងទ័ពបដិវត្តកម្ពុជា) បានបង្ហាញថា ការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ គឺជាការអនុវត្ត«មាគ៌ាពង្រឹងប្រជាជនពីខ្មាំង» ដែលបក្សកុម្មុយនីស្តកម្ពុជាធ្លាប់បានអនុវត្តកន្លងមក ។ ក្នុងបទខុទ្ទេសនាមនោះបានលើកឡើងថា«*...មាគ៌ាយើង គឺដណ្តើមប្រជាជន ១នាក់ក៏យក ២នាក់ក៏យក ១រយនាក់ក៏យក ១ពាន់នាក់ក៏យក រហូតដល់ដណ្តើមប្រជាជនពីទីក្រុងភ្នំពេញទៀត...*» ។ បក្សកុម្មុយនីស្តកម្ពុជាយល់ឃើញថា ប្រសិនបើខ្មាំងមានប្រជាជន ខ្មាំងនឹងមានយោធា និងសេដ្ឋកិច្ច ។ ផ្ទុយទៅវិញប្រសិនបើខ្មាំងពុំមានប្រជាជនទេ ខ្មាំងក៏ពុំមានយោធានិងសេដ្ឋកិច្ចដែរ ។[១៣] ថ្នាក់ដឹកនាំបក្សកុម្មុយ

---

៩-ឯកសារលេខ E1/14.1 ត្រង់ទំព័រ៦៤(បន្ទាត់ទី២-៥), ទំព័រ៧៤(បន្ទាត់ទី១០-១៩) និងទំព័រ៧៥(បន្ទាត់ ១៦-២០)

១០-ឯកសារលេខ E1/14.1 ត្រង់ទំព័រ៧៥ បន្ទាត់ទី១០-២២ ។

១១-ឯកសារលេខ E1/14.1 ត្រង់ទំព័រ៧៨ បន្ទាត់ទី៤-៩ ។

១២-យោងតាមការលើកឡើងរបស់សហព្រះរាជអាជ្ញាអន្តរជាតិ អេនឌ្រូ ខេលី បទខុទ្ទេសនាមនេះ គឺត្រូវបានថ្លែងដោយ នួន ជា ។ ឯកសារលេខ E1/14.1 ទំព័រ១៤

១៣-«ទស្សនាវដ្តីទង់បដិវត្តលេខពិសេស ធ្នូ-មករា ១៩៧៦-៧៧» ត្រង់ទំព័រទី៧០ ។

នីស្តកម្ពុជាលើកយកបទពិសោធយ៉ាងល្អពាក់ព័ន្ធនឹងការជម្លៀសយកប្រជាជនចេញពីទីក្រុងឧត្តុងភ្លាមៗ បន្ទាប់ពីវាយឈ្នះទាហាន លន់ នល់ ក្នុងអំឡុងឆ្នាំ១៩៧៤ ដោយបានលើកឡើងថា *“[...] ឧទាហរណ៍៖ យើងរំដោះឧត្តុងក្នុងឆ្នាំ១៩៧៤ ។ យើងដកយកប្រជាជនទាំងអស់ ។ ដល់វាដណ្តើមវិញ វាគ្មានកម្លាំង ។ គ្មានកម្លាំងប្រជាជន គ្មានកម្លាំងសេដ្ឋកិច្ច គ្មានកម្លាំងយោធា” ។*[១៤]

គួរបញ្ជាក់ថា ខ្លឹមសារនៃមាគ៌ាពង្រឹងប្រជាជនពីខ្មាំង ដែលថា *“...មាគ៌ាយើង គឺដណ្តើមប្រជាជន ១នាក់ក៏យក ២នាក់ក៏យក ១រយនាក់ក៏យក ១ពាន់នាក់ក៏យក រហូតដល់ដណ្តើមប្រជាជនពីទីក្រុងភ្នំពេញទៀត...”)* ត្រូវបាន ចៅក្រម ហ្សង់ម៉ាក ឡាវែង ដកស្រង់មកសួរ នួន ជា នៅក្នុងសវនាការថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ ២០១២ ។ នួន ជា បានពន្យល់ថា *“គោលការណ៍សង្គ្រាមឈ្លប ប្រជាជននៅខាងណា ខាងហ្នឹងឈ្នះ ។ យើងត្រូវពង្រឹងប្រជាជនពីខ្មាំង ។ ដូច្នោះប្រជាជននៅខាងយើង ឧបត្ថម្ភយើង ប្រជាជននៅខាងខ្មាំង ឧបត្ថម្ភខ្មាំង ។ [...]ដូច្នេះត្រូវប្រមូលប្រជាជនឲ្យបានច្រើនជាអតិបរមា ពង្រឹងប្រជាជនពីខ្មាំង” ។*[១៥]

សរុបសេចក្តីមក យោងតាមសក្ខីកម្មរបស់ នួន ជា នៅថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១១ បានបង្ហាញថា ការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ គឺត្រូវបានសម្រេចតាំងពីពាក់កណ្តាលឆ្នាំ១៩៧៤ មកម្ល៉េះ ហើយនៅតាមភូមិភាគនីមួយៗត្រូវបានណែនាំរួចជាស្រេចក្នុងការទទួលយកប្រជាជនទាំងនោះ ។ មានហេតុផលពីរយ៉ាងដែលនាំឲ្យមានការសម្រេចនេះ៖ ទី១ គឺដើម្បីជៀសវាងមិនឲ្យទាហាន លន់ នល់ នៅសម្ងំលាក់ខ្លួនក្នុងទីក្រុង ដែលអាចបង្កការរំខាន ឬវាយឆ្មក់មកលើកម្លាំងរបស់ខ្លួន និងដើម្បីពិនិត្យមើលសកម្មភាពរបស់វៀតណាម ដោយសារមានការព្រួយបារម្ភថា វៀតណាមអាចនឹងវាយដណ្តើមកាន់កាប់ទីក្រុងភ្នំពេញ បន្ទាប់ពីវៀតណាមខាងជើងរំដោះបានវៀតណាមខាងត្បូង ។ ទី២ គឺដើម្បីពង្រឹង និងពង្រីកសហករណ៍បង្កបង្កើនផលនៅតាមមូលដ្ឋាន ដែលថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជាបានសម្រេចនៅក្នុងកិច្ចប្រជុំពាក់កណ្តាលឆ្នាំ១៩៧៤ ។

បន្ថែមលើនេះទៀត យោងតាមបទឧទ្ទេសនាមរបស់ថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជាដែលត្រូវបានចុះផ្សាយក្នុងទស្សនាវដ្តីទង់បដិវត្តលេខពិសេសនោះ ការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ គឺជាការអនុវត្តមាគ៌ាយុទ្ធសាស្រ្តក្នុងការដណ្តើមយកកម្លាំងប្រជាជនពីខ្មាំង ឬនិយាយម្យ៉ាងទៀតថា គឺដើម្បីការពារមិនឲ្យមានការដណ្តើមយកប្រជាជនវិញក្នុងករណីមានខ្មាំងវាយចូលកាន់កាប់ទីក្រុងភ្នំពេញ ។

---

១៤-“ទស្សនាវដ្តីទង់បដិវត្តលេខពិសេស ធ្នូ-មករា ១៩៧៦-៧៧” ត្រង់ទំព័រទី៧១ ។

១៥-កំណត់ហេតុសវនាការលើសំណុំរឿង០០២ ចុះថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១២ ឯកសារលេខ E1/40.1 ត្រង់ទំព័រ ១៨-១៩ ។ អាចរកបានក្នុងគេហទំព័រ៖ http://www.eccc.gov.kh/document/court/16788

ថ្ងៃទី១ ខែសីហា ឆ្នាំ២០១៣

បប់